មូលនិធិខ្មែរសម្រាប់ការសិក្សា
Cambodian Education Excellence Foundation
ផ្តល់លទ្ធភាពសិក្សាស្មើភាពគ្នា    Equal Education Opportunity for All.
12739 Knightsbridge Drive, Woodbridge, VA 22192. Tel: (703) 670-0854. ceefusa@ceefoundation.org    www.ceefoundation.org

# សុន្ទរកថារបស់ អ្នកស្រី ស្មៀដ ចិន្តា

## ពិធីផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និងរៀនពូកែ

## នៅវិជ្ជាស្ថានបច្ចេកវិទ្យាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

ជាដំបូងនាងខ្ញុំសូមគោរពព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្អូនៗដែលចូលរួមក្នុងពិធីនេះ។ នាងខ្ញុំមានសេចក្តីត្រេកអរ និងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលនាងខ្ញុំមានវត្តមាននៅទីនេះ។

ខ្ញុំសូមឆ្លៀតឱកាសដ៏ល្អនៅពេលនេះ រំលឹកអំពីជីវិតរបស់ខ្ញុំ។ ការរំលឹកនេះ ដើម្បីបង្ហាញឲ្យឃើញថាហេតុអ្វីបានជាខ្ញុំមកចូលរួមក្នុងពិធីដ៏ល្អនៅថ្ងៃនេះ ?

កាលពី២៨ឆ្នាំកន្លងមកហើយ ខ្ញុំមានអាយុដំណាលស្រករនឹងប្អូនៗប្រុសស្រីទាំងអស់គ្នាដែរ ពេលនោះ ខ្ញុំមានរាងកាយស្គាំងស្គមស្លេកស្លាំង ធ្លាប់មានជម្ងឺរ៉ាំរ៉ៃប្រចាំកាយ ព្រោះអត់អាហារបរិភោគគ្រប់គ្រាន់។ នៅក្នុងរយៈ៤ឆ្នាំនោះ ខ្ញុំបាត់បង់ញាតិមិត្រ បងប្អូនជាទីស្រឡាញ់ ធ្វើឲ្យចិត្តក្តុកក្តួលគ្រាំគ្រារកថ្លែងមិនបាន ហើយត្រូវបង្ខំចិត្តកៀសខ្លួនតស៊ូដើរទៅមុខ ស្វែងរកសេរីភាព ចំណីអាហារបំពេញក្រពះ ដោយឆ្លងកាត់ព្រៃភ្នំ ដែលពេញដោយគ្រោះថ្នាក់គ្រប់បែបយ៉ាង យ៉ាងវេទនាខ្លោចផ្សាដ៏ក្រៃលែង ទំរាំនឹងបានមានភ័ព្វព្រេងវាសនា ទៅតាំងទីកន្លែង កសាងជីវិតថ្មី នៅឯសហរដ្ឋអាមេរិក។

ថ្វីត្បិតតែខ្ញុំបានខំប្រឹងប្រែងតស៊ូឧស្សាហ៍ព្យាយាមយ៉ាងស្វិតស្វាញ ធ្វើការងារយ៉ាងនឿយហត់លំបាកនៅឯសហរដ្ឋអាមេរិកយ៉ាងណាក៏ដោយ ខ្ញុំមិនអាចបំភ្លេចស្រុកកំណើតដ៏ជាទីស្រឡាញ់របស់បានទេ។ ដួងចិត្តខ្ញុំ ស្ថិតនៅទីនេះជានិច្ច ជាទីដែលខ្ញុំមានភារកិច្ចមកតបស្នងសងគុណវិញ។ ជាកិត្តិយសដ៏ប្រពៃណាស់ ដែលឲ្យឱកាសដល់ខ្ញុំមកជួយស្រុកភូមិវិញ។

នៅក្នុងជីវិតរស់នៅរបស់ប្អូនៗសព្វថ្ងៃ សូមប្អូនកុំសម្លឹងមើលឃើញតែអ្នកដែលមានជាងប្អូន។ ផ្ទុយទៅវិញ សូមប្អូនមើលទៅអ្នកដែលក្រខ្សត់ជាងប្អូនវិញ ដែលជាអ្នកត្រូវការជំនួយពីប្អូនជាចាំបាច់។ តម្លៃដ៏ល្អប្រសើរថ្លៃថ្លានៃការសិក្សាមិនស្ថិតនៅត្រង់គំនិតថា ប្អូនៗរកប្រាក់កាសបានច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណាក្រោយពីការបញ្ចប់ការសិក្សានោះទេ ។ តម្លៃសំខាន់គឺនៅត្រង់ថា ប្អូនមានលទ្ធភាពគ្រប់គ្រាន់បានមកពីការសិក្សានេះហើយយកវាទៅប្រើដើម្បីធ្វើឲ្យជីវិតបងប្អូនដែលនៅជុំវិញប្អូនៗបានប្រែក្លាយមានភាពរុងរឿងឡើងបាន ឯណោះវិញទេ។

សូមប្អូនៗសំភីចិញ្ចឹមចិត្តឲ្យមានផែនការណ៍នៅក្នុងសុបិនមួយក្នុងការធ្វើឲ្យប្រទេសកម្ពុជាត្រឡប់ទៅជាប្រទេសមួយ មានយុត្តិធម៌ និងសុខសន្តិភាពជាស្ថាពរ។ សូមប្អូនបណ្តុះសុបិនដូច្នេះឲ្យរស់រវើកឡើង។ ព្រោះថាប្រទេសកម្ពុជាយើងមាន

ពោរពេញទៅដោយកេរដំណែលមរតកវប្បធម៌យ៉ាងច្រើនសន្ធឹកសន្ធាប់អស្ចារ្យណាស់។ ថ្វីដ្បិតតែប្រទេសយើងរងគ្រោះកម្ម អភ័ព្វដោយសង្គ្រាមរាតត្បាតយ៉ាងណាក៏ដោយ បើប្អូនៗជំនាន់ក្រោយនេះ រួមជាមួយរដ្ឋាភិបាល ជនជាតិខ្មែរនៅក្រៅប្រទេស អង្គការមនុស្សធម៌ ពិភពលោកនានា ហើយនិងប្រជាជនខ្មែរទាំងមូល ចូលព្រួតដៃគ្នា ដោយចិត្តប្តេជ្ញាយ៉ាងមោះមុតដាច់ខាត ថានឹងជួយជ្រោងប្រទេសកម្ពុជានេះឲ្យផុសខ្ពស់ត្រដែតឡើងនោះ ថ្ងៃណាមួយប្រទេសយើងនឹងទៅជាប្រទេសរុងរឿង ថ្កុំថ្កើង សម្បូណ៌សប្បាយឡើងដូចដើមវិញជាមិនខាន។ ប្រទេសកម្ពុជា ជាប្រទេសមួយ មានសោភ័ណភាពល្អស្រស់បំព្រង ចិញ្ចែង ចិញ្ចាច ពាសពេញទាំងប្រទេស។ នេះដោយសារលំអដែលមាននៅក្នុងព្រលឹងនៃមនុស្ស ពោលគឺ លំអកម្ពុជា ពិតជាលំអ ដែលមាននៅក្នុងព្រលឹងប្អូនៗផងដែរ។ ដូច្នេះ នៅគ្រប់ពេលវេលាសូមប្អូនៗជួយលើកស្ទួយ លំអិតលំអ ភាពផូរផង់នេះ ឲ្យ កាន់តែប្រសើរឡើង ហើយខំថែរក្សាឲ្យនៅតែស្រស់បំព្រងប្រពៃ ឋិតថេរចីរកាលតទៅ។ សូមប្អូនៗទាំងអស់គ្នាចូលរួមក្នុងការ កសាងកម្ពុជាមួយដែលប្រកបដោយសុខសន្តិភាព និងសេចក្តីចំរើនរុងរឿង តទៅ។ សូមប្អូនៗមានជំនឿយ៉ាងមាំទៅលើ ខ្លួនឯង ទៅលើប្រជាជាតិនិងទៅលើប្រទេសជាតិរបស់យើង។

ខ្ញុំស្មានក្នុងចិត្តថា រឿងរបស់ប្អូនៗក៏ស្រដៀងនឹងរឿងរបស់ខ្ញុំដែរ។ យើងមានការលំបាកស្ទើរទ្រាំមិនបានដូចគ្នា។ ប៉ុន្តែសូម ប្អូនៗគិតថា មិនមែនបញ្ហាដែលបានកើតឡើងដល់យើងនោះទេ ដែលជាការគួរឲ្យព្រួយបារម្ភ។ ការសំខាន់នោះ គឺតើយើង ត្រូវប្រើវិធី និងមធ្យោបាយណាដើម្បីជួយរំដោះខ្លួនយើងឲ្យរួចចាកផុតពីបញ្ហាដ៏លំបាកនោះចេញបាន? បងជឿថា ប្អូនៗ អាចមានលទ្ធភាពពុះពារកផ្លូវចេញឲ្យរួចចាកផុតពីការលំបាកនោះបានដោយពិតប្រាកដ។ ហើយប្អូនៗអាចយកវាមកប្រើ ដើម្បីធ្វើឲ្យប្អូនមានភាពកាន់តែប្រសើរឡើងបាន ឲ្យមាតុភូមិដ៏ជាទីស្រឡាញ់របស់ប្អូនៗ ផ្លាស់ប្រែល្អប្លែកឡើងបាន។

ទោះបីប្អូនៗកើតនៅទីណា ឬប្រទេសណាក្តី ហើយពុំមានអ្វីសោះនោះក៏ដោយ ប្អូនៗមានកម្លាំងផ្ទាល់ខ្លួនមួយ ដែលផុសចេញ ពីខ្លួនប្អូន គឺកិត្តិយស ភាពស្និតស្នាញ និងភាពទៀងត្រង់។ ពិសេសបំផុត ប្អូនមានប្រាជ្ញា ដែលជាអានុភាពចំបង ប្អូនយកទៅ ប្រើរួមជាមួយគុណសម្បត្តិទាំងអស់ ដើម្បីលើកស្ទួយស្រុកកំណើតរបស់ប្អូន ឲ្យក្លាយទៅជាទីកន្លែងមួយដែលប្អូនអាចយកទៅ អួតអាងបាន។

**មូលនិធិខ្មែរសំរាប់ការសិក្សា** ត្រូវបានបង្កើតឡើងដោយខ្មែរ គ្រប់គ្រងដោយខ្មែរ មានគោលបំណងជួយជ្រោមជ្រែងដល់អស់ និស្សិត ដែលមានចិត្តប្រាថ្នាយ៉ាងឈ្មុសឈ្មុល តស៊ូឆ្ពោះទៅមុខជាដរាប ទោះបីមានឧបសគ្គ ឬការលំបាកយ៉ាងណាក៏ដោយ។ ពោលគឺ និស្សិតដែលប្រើប្រាជ្ញាដោះស្រាយបញ្ហាឲ្យបានសម្រេចតាមគោលការណ៍ ឲ្យខាងតែបានយ៉ាងដាច់ខាត។

ដើម្បីសម្រេចគោលបំណងនេះ ទើប**មូលនិធិខ្មែរសំរាប់ការសិក្សា** ចាំបាច់ត្រូវបានបង្កើតឡើងដើម្បីលើកស្ទួយការសិក្សា ឲ្យ បានដល់កំរិតខ្ពស់បំផុត ដោយបណ្តុះគ្រាប់ពូជ គឺប្អូនៗទាំងអស់គ្នានេះឯង ឲ្យបានដុះដាលវាលគុម្ពពាសពេញស្រែយើង។ ទាំងអស់គ្នា។ គួរយើងរំឭកឡើងវិញ នូវស្នាដៃបុព្វបុរសជីដូនជីតា និងប្រជាជនខ្មែរទាំងអស់ ដែលបានកសាងប្រាសាទល្អៗ ជាច្រើនឆ្នាំកន្លងមកហើយ សូម្បីនៅបច្ចុប្បន្ននេះក៏ប្រាសាទនៅតែល្អត្រកាល គ្មានវត្ថុណាក្នុងលោក អាចយកមកប្រៀបផ្ទឹម បានឡើយ។ ហ្ន៎! នៅទីនេះឯង ដែលកូនចៅរបស់ប្អូនៗជំនាន់ទៅមុខនឹងប្រកបជីវភាព ហើយព្រលឹងប្អូនៗក៏នឹងសំរាកនៅទី នេះ ដោយក្សេមក្សាន្ត ជាអវសាន្ត។

អ្នកទស្សនវិទូម្នាក់បានពោលថា *ការធ្វើដំណើររាប់ពាន់យោជន៍ទៅមុខគឺចាប់ផ្តើមពីជំហានទី១នេះទៅ។* ប្អូនៗអាចចាប់ ផ្តើមសួរខ្លួនឯង រៀងរាល់ថ្ងៃថា *តើខ្ញុំបានធ្វើអ្វីនៅក្នុងថ្ងៃនេះ ដែលគួរយកទៅអួតប្រាប់គេបាន?* ដូចជាគិតថា *តើខ្ញុំបាន*

*តើសសម្រាមដែលបានឃើញនោះ ចេញពីផ្លូវដែរឬ? តើខ្ញុំបានជួយជនរងគ្រោះម្នាក់ ដែលត្រូវគេវាយដុំនៅចិញ្ចើមថ្នល់នោះដែរឬទេ?* ពេលភ្ញាក់ពីព្រលឹមឡើង គិតថា *ថ្ងៃនេះជាថ្ងៃដ៏ល្អ ព្រោះខ្ញុំនឹងរកអ្វីមកធ្វើដើម្បីជាប្រយោជន៍ក្នុងការជួយអ្នកដទៃ។*

យើងចាប់ផ្តើមពីកិច្ចការតូចៗ ពីការចិញ្ចឹមចិត្តឲ្យមានសទ្ធាជ្រះថ្លា ធ្វើទាន បរិច្ចាគកម្លាំងកាយ ទ្រព្យ គំរះវិជ្ជា សំរាប់ផលប្រយោជន៍ទូទៅ។ ក្នុងជីវិតរស់នៅរាល់ថ្ងៃ សូមប្អូនៗសង្វាតធ្វើការល្អដែលអាចធ្វើទៅបាន ដូចជាថែរក្សា និងបង្ហាត់បង្រៀនក្មេងៗ ឲ្យចេះពឹងខ្លួនឯង ទប់ទល់នឹងអ្នកដែលមកបៀតបៀនរាងកាយ។ សូមប្អូនតាំងចិត្តធ្វើជាគំរូដ៏ល្អ ជាអ្នកបានសម្រេចការ សំរាប់បង្ហាញអ្នកដទៃឲ្យចេះជួយឈឺឆ្អាលក្នុងការសង្គ្រោះ។ ពិតមែនហើយថា គ្មាននរណាម្នាក់ជាបុគ្គលល្អឥតខ្ចោះនោះទេ ហើយភាពជាគំរូ អាចមានការលំបាកខ្លាំង ដើម្បីឲ្យអ្នកផងសង្ឃឹមទុកចិត្តដើរតាម។ មានអ្នកដឹកនាំជាច្រើន ដែលមានគុណវិបត្តិ ដែលពុំបានសម្រេចការ ប៉ុន្តែអ្នកទាំងនោះមិនដែលចុះចាញ់ បោះបង់ការចោលនោះសោះឡើយ។

នៅពេលរៀនចប់ មានជោគជ័យយ៉ាងណា ឬមានអំណាចយ៉ាងណានោះ សូមប្អូនបន្តកិច្ចការទៅមុខលុះត្រាប្រជាពលរដ្ឋខ្មែរគ្រប់រូបមានជីវភាពប្រសើរឡើង។ សូមប្អូនៗនឹកចាំថាយើងទាំងអស់គ្នា រួមមកនៅក្នុងគ្រួសារតែមួយ ជាមនុស្សតែមួយ ដែលរួមសុខរួមទុក្ខជាមួយគ្នា រងទុក្ខលំបាកទាំងអស់គ្នា ទោះជានៅជិតឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ។ ដូច្នេះ សូមប្អូនៗមានចិត្តស្រណោះអាណិតមេត្តាដល់ជនរួមជាតិយើងទាំងអស់គ្នា ពួតដៃរួមគ្នា ធ្វើការកសាងអនាគតភ្លឺស្វាងសំរាប់យើងទាំងអស់គ្នា ជាជាងប្រជែងប្រណាំងគ្នា។

ខ្ញុំសូមបញ្ចប់សុន្ទរកថារបស់នៅថ្ងៃនេះដោយការរំលឹកជាចុងក្រោយដូចតទៅៗ៖ នៅពេលកំពុងសិក្សាសព្វថ្ងៃ សូមប្អូនមានសុឆន្ទៈយ៉ាងមោះមុតក្នុងសុបិនមួយ ដើម្បីជួយប្រជាជាតិនិងប្រទេសរបស់ខ្លួនឲ្យបានចំរើនឡើង ដោយអស់ពីសមត្ថភាពរបស់ប្អូនៗ។ សូមរស់នៅក្នុងភាពជាអ្នកស្មោះទៀងត្រង់ ស្អាតស្អំ ជឿលើតម្លៃខ្លួនឯង និងគោរពអ្នកផងទាំងពួង។ សូមផ្តត់ផ្គង់និងរក្សាបីបាច់ដល់អ្នកដែលនៅជុំវិញខ្លួនដោយសុភាពរាបសារ និងរាប់អានបំផុត។ បងសូមជូនពរប្អូនៗ សូមបានទទួលជោគជ័យក្នុងការសិក្សា ជាពិសេស សូមប្អូនៗមានជោគជ័យស្មើភាពគ្នា ក្នុងការប្រើប្រាជ្ញា និងក្នុងដំណើរជីវិត ដើម្បីជួយកសាងប្រទេសកម្ពុជាយើង។

ខ្ញុំសូមបន្ថែមនូវពាក្យបណ្តាំដ៏មានសារៈសំខាន់ពីសមាជិកទាំងអស់នៃ**មូលនិធិខ្មែរសំរាប់ការសិក្សា** និងពីអស់អ្នកដែលបានផ្តល់វិភាគទានជួយទំនុកបំរុង**មូលនិធិ**នេះ។ យើងទាំងអស់គ្នានេះខំប្រឹងប្រែងធ្វើការដោយឥតនឿយណាយ ដើម្បីជួយទ្រទ្រង់មូលហេតុដ៏បវរនេះ។ យើងទាំងអស់គ្នាមានជំនឿ និងទុកចិត្តយ៉ាងកក់ក្តៅលើប្អូនៗគ្រប់រូប។ យើងផ្អែកនិងសង្ឃឹមលើប្អូនៗទាំងអស់ព្រោះយើងបានឃើញស្នាដៃប្អូននៅក្នុងសំណេរពាក្យសុំ ហើយនិងនៅក្នុងកែវភ្នែករបស់ប្អូនពេលនេះ។ យើងឃើញសេចក្តីប្រាថ្នាដ៏មុះមុត ការតេម្រង់ចិត្ត និងការប្តេជ្ញា ព្រមទាំងភាពស្មោះត្រង់ចំពោះប្រទេស និងប្រជាជនរបស់ប្អូន។ យើងបានជ្រើសរើសប្អូនៗទាំងអស់គ្នាមកទទួលអាហារូបករណ៍នេះដោយពិនិត្យពិច័យ ប្រិតប្រៀង យកចិត្តទុកដាក់ និងរាប់អានបំផុត។ ដូច្នេះ សូមប្អូនៗទាំងអស់គ្នា ធ្វើយ៉ាងណា ឲ្យយើងរក្សាអំនួតសរសើរពីប្អូន ដោយកុំឲ្យដាច់ពីមាត់។

សូមអរគុណ!